# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ


ACCOUNTING AND AUDITING REGULATOR

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ........✓............ន. គ. ស .......


ថ្ងៃព្រហ. ១៤រោច ខែ អាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែកក្កដា គ.ស.២០២៥

## សេចក្តីជូនដំណឹង
## ស្តីពី
## ការបិទបញ្ចប់ក្នុងការទទួលលិខិតស្នើសុំពន្យារពេលសម្រាប់បញ្ចប់ការងារសវនកម្មឯករាជ្យ និងបោះផ្សាយមតិសវនកម្មឯករាជ្យ សម្រាប់ការិយបរិច្ឆេទគណនេយ្យ២០២៤ មកនិយ័តករគណនេយ្យនិងសវនកម្ម

និយ័តករគណនេយ្យនិងសវនកម្ម (**ន.គ.ស.**) នៃ អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) សូមជម្រាបជូន លោក លោកស្រី ជាម្ចាស់សហគ្រាស និងប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ(អង្គភាព) រងសវនកម្មឯករាជ្យជ្រាបថា៖ យោងតាមសេចក្តីជូនដំណឹងចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៥ ស្តីពីការពន្យារពេលវេលាបន្ថែមក្នុងការទទួលលិខិតស្នើសុំពន្យារពេលសម្រាប់បញ្ចប់ការងារសវនកម្មឯករាជ្យ និងបោះផ្សាយមតិសវនកម្មឯករាជ្យ សម្រាប់ការិយបរិច្ឆេទគណនេយ្យ២០២៤ ***ត្រូវបានផុតកំណត់ត្រឹមថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៥***។ ជាក់ស្តែងរហូតមកដល់ពេលនេះ នៅមានសហគ្រាសនិងអង្គភាពមួយចំនួនមានភាពយឺតយ៉ាវក្នុងការដាក់ពាក្យស្នើសុំពន្យារពេលបញ្ចប់ការងារសវនកម្មឯករាជ្យ និងបោះផ្សាយមតិសវនកម្មឯករាជ្យ មក **ន.គ.ស.** តាមកាលកំណត់ខាងលើនេះ។

ដើម្បីផ្តល់ភាពទន់ភ្លន់ **ន.គ.ស.** សម្រេចផ្តល់ពេលវេលា ចំនួន១៥ ថ្ងៃបន្ថែមទៀត សម្រាប់សហគ្រាស និងអង្គភាពរងសវនកម្មឯករាជ្យ ក្នុងការដាក់លិខិតស្នើសុំពន្យារពេលសម្រាប់បញ្ចប់ការងារសវនកម្មឯករាជ្យ និងបោះផ្សាយមតិសវនកម្មឯករាជ្យ សម្រាប់ការិយបរិច្ឆេទគណនេយ្យ២០២៤ ដោយសហគ្រាស និងអង្គភាព ត្រូវដាក់លិខិតស្នើសុំពន្យារពេលសម្រាប់ការបញ្ចប់ការងារសវនកម្មឯករាជ្យ និងបោះផ្សាយមតិសវនកម្មឯករាជ្យមក **ន.គ.ស.** មិនឱ្យហួស***ថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៥***។

បញ្ជាក់៖ សហគ្រាស និងអង្គភាពត្រូវបង់កម្រៃសេវាតាមប្រកាសលេខ០០២ អ.ស.ហ. ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៥ ស្តីពីសេវាសាធារណៈរបស់និយ័តករគណនេយ្យនិងសវនកម្មជាធរមាន។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងមន្ត្រី ន.គ.ស. តាមរយៈលេខទូរស័ព្ទ និងតេឡេក្រាមដូចខាងក្រោម៖

- សម្រាប់សហគ្រាស ៖ ០៩៦ ៩ ១៩៩ ៩៩៨/ ០៧៧ ៨០៥ ៥៥២/ ០១០ ៦៩៤ ៦២២/ ០១៦ ៥៩៨ ៣៨៦។
- សម្រាប់អង្គភាព ៖ ០៨១ ៦៤៤ ៦៦៣/ ០៩២ ៦៨៨ ២៩៧/ ០៨៥ ៩០៤ ៨៤៨/ ០៨៥ ៤៤៤ ៤៨៨។

***ការខកខានមិនបានដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុរងសវនកម្មឯករាជ្យប្រចាំឆ្នាំ២០២៤ មក ន.គ.ស. ជាកម្មវត្ថុនៃការអនុវត្តវិធានការតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។***

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមម្ចាស់សហគ្រាស និងប្រធានអង្គភាពរងសវនកម្មឯករាជ្យ ជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តខ្លឹមសារនៃសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

**និយ័តករគណនេយ្យនិងសវនកម្ម**

ដើម្បីទទួលបាន ឬសាកសួរព័ត៌មាន
អំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
សូមចូលរួមក្នុង Telegram Channel របស់ ន.គ.ស